**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាល លើកទី៧ អាណត្តិទី១ របស់ ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី

នាថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ ចាប់ពីម៉ោង ១៤ : ០០ រសៀល នៅទីស្នាក់ការក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី ដែលមានទីតាំងនៅ ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា លោក **យ៉ាង សាវស៊ីន** ប្រធានក្រុមប្រឹក្សាភិបាល នៃក្រុមហ៊ុន ហ្គ្រេន ធ្វីន បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី ៧ របស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី (**ហ.ធ.អ**)។

**<u>សមាសភាពចូលរួមរបស់អភិបាល</u>**

| | | |
|---|---|---|
| ១. លោក | **យ៉ាង សាវស៊ីន** | ប្រធានក្រុមប្រឹក្សាភិបាល |
| ២. ឧកញ៉ា | **លី យុនថៃ** | អភិបាលឯករាជ្យ |
| ៣. លោក | Chen Tsung-Chi | អភិបាល |
| ៤. លោក | Liao Chung-Te | អភិបាល |
| ៥. លោកស្រី | Su Yu Chin | អភិបាល |

នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី ៧ នេះ អង្គប្រជុំបានពិនិត្យ និងពិភាក្សាយ៉ាងផុសផុលលើខ្លឹមសារលម្អិតនៃរបាយការណ៍ប្រតិបត្តិការរបស់ ក្រុមហ៊ុន ហ្គ្រេន ធ្វីន ដែលទទួលបានលទ្ធផល និងអនុម័តដូចខាងក្រោម៖

## ១. លទ្ធផលប្រតិបត្តិការក្រុមហ៊ុនសម្រាប់ឆ្នាំ២០១៤

របាយការណ៍លទ្ធផលហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៤ ដែលធ្វើសវនកម្មរួចដោយសវនករឯករាជ្យ ដែលជាលទ្ធផលក្រុមហ៊ុនទទួលបានចំណេញក្រោយបង់ពន្ធ ចំនួន ១៤.១៤៧.៥០៨.០០០ រៀល។

## ២. គោលការណ៍បែងចែកប្រាក់ចំណេញ ឆ្នាំ២០១៤

ប្រាក់ចំណេញទទួលបានក្រោយបង់ពន្ធ ចំនួន ១៤.១៤៧.៥០៨.០០០ រៀល នឹងត្រូវធ្វើបែងចែកដូចខាងក្រោម៖

ក. ប្រាក់ចំណេញរក្សាទុក មានទឹកប្រាក់ចំនួន ៧.០៧៣.៧៥៤.០០០ រៀល

ខ. បែងចែកភាគលាភដល់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនធម្មតារបស់ក្រុមហ៊ុន ហ្គ្រេន ធ្វីន៖

- ប្រភេទភាគលាភដែលបែងចែក : ជាសាច់ប្រាក់
- រយៈពេលភាគលាភ : ប្រចាំឆ្នាំ២០១៤
- អនុបាតនៃការបែងចែកភាគលាភ : ៥០%
- ភាគលាភសរុបដែលបែងចែក : ៧.០៧៣.៧៥៤.០០០ រៀល
- ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធ : ១៧៧ រៀល
- កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកត្រូវទទួលបានភាគលាភ : ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥
- កាលបរិច្ឆេទចាប់ផ្តើមទូទាត់ភាគលាភ : ថ្ងៃទី២២ ខែមិថុនា ឆ្នាំ ២០១៥

## ៣. ផែនការយុទ្ធសាស្ត្រ និងទិសដៅសម្រាប់ត្រីមាសបន្ទាប់ៗ ឆ្នាំ២០១៥

របាយការណ៍លទ្ធផលហិរញ្ញវត្ថុក្នុងគ្រាសង្ខេប (បណ្តោះអាសន្ន) សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៥ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ (មិនទាន់ធ្វើសវនកម្ម) ដែលចេញដោយសវនករឯករាជ្យ ក្រុមហ៊ុនទទួលបានចំណេញ ក្រោយបង់ពន្ធចំនួន ២.៥២០.៥៨៦.០០០ រៀល ។

ក្រុមហ៊ុននឹងនៅតែខិតខំប្រឹងប្រែងរក្សាទំនាក់ទំនងយ៉ាងល្អជាមួយអតិថិជនរបស់ខ្លួន ជាពិសេសអតិថិជនចម្បងគឺ Adidas ក្នុងគោលបំណងទទួលបានការកើនឡើងនៃការបញ្ជាទិញត្រីមាសបន្ទាប់ សម្រាប់ឆ្នាំ២០១៥ និងព្យាយាមក្នុងការសហការជាមួយដៃគូនានា ដើម្បីទទួលបានចំណូលផ្សេងៗទៀត ដូចជា តាមរយៈការទទួលដេរបន្ត ការកាត់ ដេរ និងវេចខ្ចប់ ដើម្បីរក្សាស្ថេរភាព និងបង្កើនចំណូលឲ្យបានច្រើនជាងបណ្តាឆ្នាំកន្លងទៅសម្រាប់ក្រុមហ៊ុន។ ចំពោះត្រីមាសទី២ ឆ្នាំ២០១៥ ក្រុមហ៊ុន ហ្គ្រេន ធ្វីន នឹងខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីធ្វើឲ្យកាន់តែប្រសើរឡើង ក្នុងការពង្រឹងអភិបាលកិច្ចសាជីវកម្មល្អរបស់ក្រុមហ៊ុន ហើយនៅតែប្រកាន់ខ្ជាប់នូវទស្សនវិស័យ និងបេសកកម្ម ដែលបានកំណត់ពីឆ្នាំមុនៗ។

អង្គប្រជុំបានបញ្ចប់ទៅនៅវេលាម៉ោង ១៧:៣០ ល្ងាច នាថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសទទួលខុសត្រូវខ្ពស់ និងឯកភាពគ្នា។

**ក្រុមហ៊ុន ហ្គ្រេន ធ្វីន អិនធើណេសិនណាល (ខេមបូឌា) ភីអិលស៊ី**

ទីស្នាក់ការ: ភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ:(៨៥៥)២៣ ៨៩០ ៣២៥ /ទូរសារ : (៨៥៥)២៣ ៨៩០ ៣២៦/ គេហទំព័រ : www.Grandtwins.com.kh/ អ៊ីម៉ែល : vuthy.phuong@qmico.com